ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ១៣៩ សកបយ

## ប្រកាសរួម
## ក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា
## និង ក្រសួងសុខាភិបាល
## ស្តីពី លក្ខខណ្ឌនិងបេសកកម្មរបស់គ្រូពេទ្យសហគ្រាស

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល
### រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨-៧២ចុះថ្ងៃទី៣០-១១-១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០-៧-១៩៩៤ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣-៣-១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខនស/រកម/០៦៩៩-០៦ចុះថ្ងៃទី១៧-៦-១៩៩៩ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤-០១-៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញអនុក្រឹត្យលេខ៨៧ អនក្រ.បក ចុះថ្ងៃទី០៤-១០-១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២-១០-៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

### សំរេច

ប្រការ១.- គ្រូពេទ្យដែលអាចធ្វើការនៅក្នុងតិលានដ្ឋានសហគ្រាសបាន លុះត្រាតែបានបំពេញនូវល័ក្ខខ័ណ្ឌ ដូចខាងក្រោមនេះ ៖

-មានសញ្ជាតិខ្មែរ

-មានសញ្ញាប័ត្រវេជ្ជសាស្ត្រដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល

-បានទទួលការអប់រំបន្ថែមអំពីអនាម័យការងារនិងបច្ចេកទេសសុវត្ថិភាពការងារ នៅនាយកដ្ឋានពេទ្យការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានចុះឈ្មោះនៅក្នុងបញ្ជីសមាជិកគណៈគ្រូពេទ្យ

-មិនដែលមានទោសពីបទព្រហ្មទណ្ឌណាមួយ

-មានសុខភាពគ្រប់គ្រាន់អាចបំពេញការងារនេះបាន

-មានលិខិតអនុញ្ញាតប្រកបមុខរបរជាគ្រូពេទ្យសហគ្រាសដែលចេញឱ្យពីរឆ្នាំម្តងដោយនាយកដ្ឋានពេទ្យការងារ ។

ប្រការ២.- គ្រូពេទ្យសហគ្រាសមានសិទ្ធិនិងកាតព្វកិច្ចមួយចំនួនដូចតទៅ ៖

-ត្រូវមានកិច្ចសន្យាការងារមួយឆ្នាំម្តង ហើយចម្លងជូនទៅនាយកដ្ឋានពេទ្យការងារ

-ទទួលប្រាក់ឈ្នួលតាមកិច្ចសន្យាពីសហគ្រាស **និងមានសិទ្ធិទទួលនូវការឧបត្ថម្ភនិងសិទ្ធិផ្សេងៗ ដទៃទៀត ដូចកម្មករនិយោជិតក្នុងសហគ្រាស**

-មានសិទ្ធិប្រកបមុខវិជ្ជាជីវៈតាមល័ក្ខខ័ណ្ឌបច្ចេកទេសរបស់ខ្លួន

-មានតួនាទីជាទីប្រឹក្សាផ្នែកអនាម័យនិងសន្តិសុខការងាររបស់សហគ្រាស ។ ប្រសិនបើការផ្តល់យោបល់ដ៏ត្រឹមត្រូវមិនបានទទួលស្គាល់ពីសហគ្រាស ត្រូវរាយការណ៍ជាបន្ទាន់ទៅអធិការពេទ្យការងារ ឬអធិការការងារ

-ត្រូវចេះរក្សាអាថ៌កំបាំងវិជ្ជាជីវៈពេទ្យ និងអាថ៌កំបាំងបច្ចេកទេស របបផែនផលិតរបស់សហគ្រាស

-ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងសីលធម៌វិជ្ជាជីវៈនៃនាយកដ្ឋានពេទ្យការងារ ។

ប្រការ៣.- បេសកកម្មនៃគ្រូពេទ្យសហគ្រាសមានដូចតទៅ ៖

១- ធ្វើការងារបង្ការសុខភាពកម្មករនិយោជិតឱ្យគេចផុតពីគ្រោះថ្នាក់ការងារនិងជម្ងឺវិជ្ជាជីវៈ ជាការងារចំបងរបស់គ្រូពេទ្យសហគ្រាស រួមមានជាអាទិ៍ ៖

-ពិនិត្យទីកន្លែងធ្វើការឱ្យបានទៀងទាត់និងជាកាលិក ដើម្បីសិក្សាអំពីល័ក្ខខ័ណ្ឌការងារ ប៉ុស្តិ៍ការងារ បច្ចេកទេសផលិត អំពីសារធាតុនានាដែលមានប្រើក្នុងផលិតកម្ម និងអំពីស្ថានភាពសុវត្ថិភាពគ្រឿងចក្រនានា

-ឃ្លាំមើលស្ថានភាពសុខភាពកម្មករនិយោជិត ដោយផ្តល់ពត៌មានឬឱ្យដំបូន្មានដល់កម្មករនិយោជិត អំពីយថាហេតុនៃការថមថយកាយសម្បទារបស់គេ ឬយថាហេតុនៃគ្រោះថ្នាក់ការងារ និងជម្ងឺវិជ្ជាជីវៈ

-ឃ្លាំមើលបរិស្ថានជុំវិញនិងស្ថានភាពនៃអនាម័យទូទៅរបស់សហគ្រាសនៅការិយាល័យ រោងជាង អាហារដ្ឋាន វាសនដ្ឋាន ។ល។

-ផ្តល់សេវាសង្គ្រោះបន្ទាន់ដល់កម្មករនិយោជិតដែលទទួលរងគ្រោះថ្នាក់ការងារ

-ពិនិត្យព្យាបាលបឋមដល់កម្មករនិយោជិតដែលមានជម្ងឺផ្សេងៗ ។

២- ធ្វើការងាររដ្ឋបាលមួយចំនួនដែលចាំបាច់ដូចជា ៖

-ត្រូវរក្សាការសម្ងាត់រាល់ឯកសារស្តីពីសុខភាពរបស់កម្មករនិយោជិត

-រៀបចំសាលាកប័ត្រពេទ្យសំរាប់ផ្តល់ឱ្យកម្មករនិយោជិតនៅពេលដែលគេចាកចេញពីសហគ្រាស

-ត្រូវរក្សាទុកដាក់ឱ្យមានសណ្តាប់ធ្នាប់រាល់សៀវភៅបញ្ជីផ្សេងៗរបស់គិលានដ្ឋាន(បញ្ជីប្រចាំថ្ងៃ បញ្ជីកម្មករនិយោជិតដែលធ្វើការជាប់និងគ្រោះថ្នាក់ បញ្ជីចាក់ថ្នាំបង្ការ ។ល។

-ធ្វើសេចក្តីជូនដំណឹងអំពីគ្រោះថ្នាក់ការងារនិងជម្ងឺវិជ្ជាជីវៈអំពីជម្ងឺឆ្លងជាដើមទៅផ្នែកនិងស្ថាប័នពាក់ព័ន្ធ/.

-ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ទៅនាយកដ្ឋានពេទ្យការងារ ។

៣- ធ្វើការទំនាក់ទំនងនៅក្នុងនិងក្រៅសហគ្រាស ៖

-នៅក្នុងសហគ្រាស ត្រូវធ្វើទំនាក់ទំនងជាមួយទីចាត់ការ ផ្នែកផែនការផលិតកម្ម ប្រតិភូបុគ្គលិក និងសហជីព គណៈកម្មការអនាម័យនិងសន្តិសុខសហគ្រាស ។ល។

-នៅក្រៅសហគ្រាស ត្រូវធ្វើទំនាក់ទំនងជាមួយគ្រូពេទ្យព្យាបាលនៅតាមមន្ទីរពេទ្យ អធិការពេទ្យការងារ អធិការការងារ ឬមន្ទីរពិសោធន៍ផ្សេងៗ ។

ប្រការ៤.- និយោជក ឬតំណាងនិយោជក ត្រូវទុកឱកាសនិងផ្តល់សិទ្ធិចាំបាច់ឱ្យគ្រូពេទ្យសហគ្រាសអនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ។

ប្រការ៥.- ការបញ្ឈប់គ្រូពេទ្យសហគ្រាស មុនកិច្ចសន្យាការងារផុតកំណត់ ត្រូវមានការពិគ្រោះយោបល់ជាមុនជាមួយអធិការពេទ្យការងារ ។

ប្រការ៦.- គ្រូពេទ្យសហគ្រាសដែលបានបំពេញការងារនៅក្នុងសហគ្រាសមុនប្រកាសនេះចេញ ត្រូវមកបំពេញល័ក្ខខ័ណ្ឌដូចមានចែងក្នុងប្រការ១នៃប្រកាសនេះ ។

ប្រការ៧.- ការមិនអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ ។

ប្រការ៨.- ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០០១

រដ្ឋមន្ត្រី
ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

អ៊ិត សំហេង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសុខាភិបាល

ហុង ស៊ុនហួត

ចម្លងជូន :
- ព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋាន ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
"ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
- គ្រប់មន្ទីរសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
- គ្រប់ម្ចាស់និយោជក "ដើម្បីអនុវត្ត"
- សហភាពសហជីព "ដើម្បីជ្រាប"
- គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- កាលប្បវត្តិ និងឯកសារ